ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៧ ព.ណ.ចរ.ប្រក

# ប្រកាស
# ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់
# នាយកដ្ឋានអាមេរិក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១**:

នាយកដ្ឋានអាមេរិកបំពេញមុខងារ ជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិលើការងារពាក់ព័ន្ធជាមួយទ្វីបអាមេរិក មានមុខងារនិងភារកិច្ច ដូចតទៅៈ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅទ្វីបអាមេរិក
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគីជាមួយបណ្តាប្រទេសនៅទ្វីបអាមេរិក



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

- សហការជាមួយអង្គភាពនិងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារ សម្រប សម្រួលនិងជំរុញពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅទ្វីបអាមេរិក
- ប្រតិបត្តិរាល់គោលនយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជ-កម្មអន្តរជាតិជាមួយបណ្តាប្រទេសនៅទ្វីបអាមេរិក
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំង ពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការធ្វើពាណិជ្ជកម្មជាមួយបណ្តាប្រទេស នៅទ្វីបអាមេរិក
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀង ពាណិជ្ជកម្មរបស់កម្ពុជាជាមួយបណ្តាប្រទេសនៅទ្វីបអាមេរិក
- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈនៃការយោគយល់គ្នា របស់កម្ពុជា ក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយបណ្តាប្រទេសនៅទ្វីបអាមេរិក
- សហការជាមួយអង្គភាពនិងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាង សមត្ថភាព កិច្ចប្រជុំ សិក្ខាសាលា វេទិកានានា និងផ្សព្វផ្សាយលទ្ធផលនៃការចរចា បើកច្រកទីផ្សារសម្រាប់ទំនិញ សេវាកម្ម និងកិច្ចព្រមព្រៀងដទៃទៀត ជូនដល់មន្ត្រី រាជការ សិស្ស និស្សិត និងវិស័យឯកជន
- ស្រាវជ្រាវ ចងក្រងព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច ពាណិជ្ជកម្មនៅទ្វីបអាមេរិក
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្មនៅទ្វីប អាមេរិក
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ២**:

នាយកដ្ឋានអាមេរិកដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៣**:

នាយកដ្ឋានអាមេរិកមានការិយាល័យចំណុះចំនួន ៣ គឺ៖

១. ការិយាល័យ សហរដ្ឋអាមេរិក

២. ការិយាល័យ កាណាដា

៣. ការិយាល័យ អាមេរិកខាងត្បូង

ការិយាល័យនីមួយៗគ្រប់គ្រងដោយប្រធានការិយាល័យមួយរូប និងអនុប្រធានការិយាល័យ មួយចំនួនជាជំនួយការ។

**ប្រការ៤**:

ការិយាល័យ សហរដ្ឋអាមេរិក មានមុខងារ និងភារកិច្ច ដូចតទៅ៖

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ជាមួយសហរដ្ឋអាមេរិក

- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាទ្វេភាគីជាមួយសហរដ្ឋអាមេរិក
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារសម្រួលនិងជម្រុញពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក
- ប្រតិបត្តិរាល់គោលនយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជ-កម្មជាមួយសហរដ្ឋអាមេរិក
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយសំដៅសម្រួលការធ្វើពាណិជ្ជកម្ម
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជា និងសហរដ្ឋអាមេរិក
- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈនៃការយោគយល់គ្នាក្នុងក្របខ័ណ្ឌទ្វេភាគី
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព កិច្ចប្រជុំ សិក្ខាសាលា វេទិកានានា និងផ្សព្វផ្សាយលទ្ធផលនៃការចរចាបើកច្រកទីផ្សារសម្រាប់ទំនិញ សេវាកម្ម និងកិច្ចព្រមព្រៀងដទៃទៀត ជាមួយសហរដ្ឋ-អាមេរិក ជូនដល់មន្ត្រីរាជការ សិស្ស និស្សិត និងវិស័យឯកជន
- ស្រាវជ្រាវ ចងក្រងព័ត៌មាន និងទិន្នន័យពាណិជ្ជកម្មនៅសហរដ្ឋអាមេរិក
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្មនៅសហរដ្ឋអាមេរិក
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ៥**:

ការិយាល័យ កាណាដា មានមុខងារ និងភារកិច្ច ដូចតទៅ៖

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ជាមួយកាណាដា
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាទ្វេភាគីជាមួយកាណាដា
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារសម្រួលនិងជំរុញពាណិជ្ជកម្មជាមួយកាណាដា
- ប្រតិបត្តិរាល់គោលនយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជ-កម្មជាមួយកាណាដា
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការធ្វើពាណិជ្ជកម្ម

- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជា និងកាណាដា
- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈនៃការយោគយល់គ្នាក្នុងក្របខ័ណ្ឌទ្វេភាគី
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព កិច្ចប្រជុំ សិក្ខាសាលា វេទិកានានា និងផ្សព្វផ្សាយលទ្ធផលនៃការចរចាបើកច្រកទីផ្សារសម្រាប់ទំនិញ សេវាកម្ម និងកិច្ចព្រមព្រៀងដទៃទៀតជាមួយកាណាដា ជូនដល់មន្ត្រីរាជការ សិស្ស និស្សិត និងវិស័យឯកជន
- ស្រាវជ្រាវ ចងក្រងព័ត៌មាន និងទិន្នន័យពាណិជ្ជកម្មនៅកាណាដា
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្មនៅកាណាដា
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ៦**:

ការិយាល័យ អាមេរិកខាងត្បូង មានមុខងារ និងភារកិច្ច ដូចតទៅ៖

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅទ្វីបអាមេរិកខាងត្បូង ក្រៅពីសហរដ្ឋអាមេរិក និងកាណាដា
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាទ្វេភាគីជាមួយទ្វីបអាមេរិកខាងត្បូង
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារសម្រួល និងជម្រុញពាណិជ្ជកម្មជាមួយទ្វីបអាមេរិកខាងត្បូង
- ប្រតិបត្តិរាល់គោលនយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជកម្មជាមួយទ្វីបអាមេរិកខាងត្បូង
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការធ្វើពាណិជ្ជកម្ម
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា និងប្រទេសនៅទ្វីបអាមេរិកខាងត្បូង
- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈនៃការយោគយល់គ្នាក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសនៅទ្វីបអាមេរិកខាងត្បូង
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព កិច្ចប្រជុំ សិក្ខាសាលា វេទិកានានា និងផ្សព្វផ្សាយលទ្ធផលនៃការចរចា

បើកច្រកទីផ្សារសម្រាប់ទំនិញ សេវាកម្ម និងកិច្ចព្រមព្រៀងដទៃទៀត ជាមួយប្រទេសនៅទ្វីបអាមេរិកខាងត្បូង ជូនដល់មន្ត្រីរាជការ សិស្ស និស្សិត និងវិស័យឯកជន

- ស្រាវជ្រាវ ចងក្រងព័ត៌មាន និងទិន្នន័យពាណិជ្ជកម្ម ប្រទេសនៅទ្វីបអាមេរិកខាងត្បូង
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្ម នៅទ្វីបអាមេរិកខាងត្បូង
- សម្របសម្រួលកិច្ចការរដ្ឋបាលទូទៅរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ៧**:

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទ ត្រូវអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

<u>កន្លែងទទួល</u>:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធរបស់នាយកដ្ឋានអាមេរិក

